**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមប្រឹក្សា
កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
អគ្គលេខាធិការដ្ឋាន
លេខៈ០២៩/០៩ រប.កកចយ

## របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ធ្នូ ឆ្នាំ ២០០៩របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែធ្នូ ឆ្នាំ២០០៩ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បាន ដំណើរការងាររបស់ខ្លួន ស្របតាមបេសកកម្មដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ហើយ សម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

## ១-លទ្ធផលដែលអនុវត្តបាន

### ក. ការងាររដ្ឋបាល

- ផ្ញើលិខិតលេខ ០៩៦/០៩ លអ.កកចយ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ សំណើសុំចាត់តាំងតំណាង ០១ រូប ដើម្បីចូលរួមផ្តល់យោបល់លើសេចក្តីព្រាងអនុក្រឹត្យស្តីពីសាលាជំម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា

-ផ្ញើលិខិតលេខ ០៩៧/០៩ លប.កកចយ ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០០៩ នូវលិខិតបញ្ជាក់ជូនកញ្ញា ជា សុភី

-ផ្ញើលិខិតលេខ ០៩៩/០៩ លអ.កកចយ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៩ សំណើសុំចាត់តាំងតំណាង ០១ រូប ចូលរួមប្រជុំ ដើម្បីរៀបចំ “កម្រងសេវាយុត្តិធម៌” ដែលប្រព្រឹត្តទៅនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩

-ផ្ញើលិខិតលេខ ១០០/០៩ លអ.កកចយ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩ សំណើសុំចាត់តាំងតំណាង (០១) រូមចូលរួមប្រជុំ ប្រចាំឆ្នាំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ (TWG/LJR)នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ នៅសណ្ឋាគារ សាន់វេ

-ផ្ញើលិខិតលេខ១០១/០៩ លស.កកចយ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ សំណើសុំបញ្ជូនតារាងបញ្ជីសារពើភ័ណ្ឌនៃការកើន ឡើងទ្រព្យសម្បត្តិរដ្ឋសម្រាប់ឆ្នាំ២០០៩ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-ផ្ញើលិខិតលេខ ១០២/០៩ លស.កកចយ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩ សំណើសុំអនុញ្ញាតទៅចូលរួមសន្និសីអន្តរជាតិ ស្តីពីកិច្ចសហប្រតិបត្តិការគ្រប់គ្រងការពង្រឹងលំហរទំនិញ និងផលប៉ះពាល់លើកំណែទម្រង់ច្បាប់ក្នុងតំបន់-ទស្សនៈវិស័យពីអ្នកផ្តល់ និងអ្នកទទួលនៅទីក្រុងណាកូយ៉ា ប្រទេសជប៉ុន

-ផ្ញើលិខិតលេខ ១០៣/០៩ លស.កកចយ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩ សំណើសុំផ្តល់យោបល់លើសំណើក្របខ័ណ្ឌនៃការអនុវត្តប្រព័ន្ធអំប៊ូស្មាន់ (Ombudsman )នៅកម្ពុជា

-បានទទួលលិខិតលេខ ០២៨ ដនស/អរប/រប ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នូវរបាយការណ៍បូកសរុបលទ្ធផលអនុវត្តការងារ ០៩ ខែ ឆ្នាំ២០០៩ និងទិសដៅបន្ត

-បានទទួលលិខិតលេខ ៤៧៧ លអជ.រប ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ អញ្ជើញចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុសញ្ញាកុងស៊ុលរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលនឹងប្រព្រឹត្ត ទៅនៅថ្ងៃអង្គារ៍ទី០១ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ០៨ះ៣០ នាទី

-បានទទួលលិខិតលេខ ១០០៣/០៩/របវត/អគជ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ពីរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ នូវលិខិតអញ្ជើញ ចៅក្រម និងព្រះរាជអាជ្ញា ចូលរួមវគ្គបណ្តុះបណ្តាលបន្តស្តីពី“ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ ភូមិបាល”ចាប់ពីថ្ងៃទី១៤-១៨ ខែធ្នូ ឆ្នាំ២០០៩ និងវគ្គបណ្តុះបណ្តាលបន្តស្តីពី “ សេចក្តីព្រាងក្រមព្រហ្មទណ្ឌ-ក្រមនីតិវិធីព្រហ្មទណ្ឌ និងអំពើធ្វើអាជីកម្មផ្លូវភេទ ” ចាប់ពីថ្ងៃ២១-២៥ ខែធ្នូ ឆ្នាំ២០០៩

-បានទទួលលិខិតលេខ ៤៧៨ លអជ.រប ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ អញ្ជើញចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បី ពិភាក្សាលើៈ ១- សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ២- សេចក្តីព្រាងអនុក្រឹត្យស្តីពីវិធាននៃការបង្កើត និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០២-០៣ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ៨ះ៣០

-បានទទួលលិខិតលេខ ៤៨៦ លអជ.រប ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ អញ្ជើញចូលរួមក្នុងអង្គប្រជុំអន្តរក្រសួងដើម្បី ពិភាក្សាបន្តសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធាននៃការបង្កើត និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការភូមិ ដែលប្រព្រឹត្តទៅនៅថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ៨ះ៣០នាទី

-បានទទួលលិខិតលេខ ១៩២០ លស.បល ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៩ សំណើសុំផ្តល់របាយការណ៍ ស្តីពីការបណ្តុះបណ្តាលមន្ត្រីរាជការចាប់ពី ០១ សប្តាហ៍ឡើងទៅដែលបានសិក្សាក្នុង និងក្រៅប្រទេសសម្រាប់ឆ្នាំ២០០៩

-បានទទួលលិខិតលេខ ៤៩១ លអជ.រប ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩ អញ្ជើញចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គសេនាបីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាដើម្បីពិភាក្សាលើ របៀបវារៈដូចខាងក្រោមៈ១-សេចក្តីព្រាងច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ និង ២-បញ្ហាផ្សេងៗ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ៨ះ៣០ នាទីព្រឹក

-បានទទួលលិខិតលេខ ៤៨៨ លអជ.រប ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៩ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបិទសិក្ខាសាលា ស្តីពី“ការប្រយុទ្ធទប់ស្កាត់អំពើចារកម្ម ការចរាចរនិងជួញដូរវត្ថុបុរាណខុសច្បាប់” រៀបចំឡើងដោយអង្គការយូណេស្កូកម្ពុជា និង ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិយូណេស្កូកម្ពុជា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ១៥ះ៤៥នាទី“ពិធីបិទចាប់ផ្តើម”

-បានទទួលលិខិតលេខ ៤៩០ លអជ.រប ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៩ ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធជានិមិត្តរូប របស់វិទ្យាស្ថាន Khong ZI ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ០៨ៈ៣០ នាទី “ ចាប់ផ្តើមពិធី”

-បានទទួលលិខិតលេខ ៤៩៥ លអជ.រប ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីប្រកាសនិងផ្សព្វផ្សាយអំពី“ការប្រព្រឹត្តទៅរបស់គណៈវិស្វករកម្ពុជា” ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង៣ៈ៣០នាទី នៅសណ្ឋាគារ ណាហ្គាវើល

-បានទទួលលិខិតលេខ ៤៦៧ លអជ.រប ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៩ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធ សាលពិព័ណ៌សិល្បៈវប្បធម៌ពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមសុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួល បន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩

-បានទទួលលិខិតលេខ ៤៩៨ លអជ.រប ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួងដើម្បីពិភាក្សាបន្ត លើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការប្រែក្លាយមន្ទីរពេទ្យកុមារជាតិ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៦-១៧ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង៨ៈ៣០ នាទី

-បានទទួលលិខិតលេខ ៥០២ លអជ.រប ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើ សេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ១៥ៈ០០ នាទី

-បានទទួលលិខិតលេខ ១០៦០/របវត/អគជ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩ ចូលរួមក្នុងពិធីធ្វើសច្ចាប្រណិធានរបស់សិស្ស ថៅក្រមជំនាន់ទី៥ ដើម្បីទៅធ្វើកម្មសិក្សានៅតាមសាលាជម្រះក្តីនានា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ នៅ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

-បានទទួលលិខិតពីអង្គការយូអិនឌីភី (UNDP) ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការអញ្ជើញចូលរួមប្រជុំក្រុមប្រត្តិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ នៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី វេលាម៉ោង ១៤ៈ៣០

-បានទទួលលិខិតលេខ ២០៩៣ កយរប/០៩ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ពីក្រសួងយុត្តិធម៌ ស្តីពីសំណើសុំធ្វើការកែ សម្រួលលើចំណុចមួយចំនួននៃសេចក្តីព្រាងអនុក្រឹត្យស្តី ពីរដ្ឋបាលសាលាជម្រះក្តី នៃព្រះរាជាណាចក្រកម្ពុជា

-បានទទួលលិខិតលេខ ៥១៥ លអជ.រប ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ ចូលរួមប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីប្រព័ន្ធមរតិមនុស្សរស់ នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ម៉ោង ៨ៈ៣០នាទី

-បានទទួលលិខិតលេខ ៥១៦ លអជ.រប ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញា បត្រជូនដល់និស្សិត ថ្នាក់បរិញ្ញាបត្ររង បរិញ្ញបត្រ បរញ្ញាបត្រជនខ្ពស់ និងបណ្ឌិត នៃសកលវិទ្យាល័យបៀលប្រាយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ដែលប្រព្រឹត្ត ទៅនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០ នាទី នៅវិទ្យាស្ថានជាតិអប់រំ

-បានទទួលលិខិតលេខ ១១៣០/០៩ របវត/អគជ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៩ ចូលរួមប្រជុំក្រុមប្រឹក្សាភិបាលលើកទី១១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ១៥ៈ៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី

-បានទទួលលិខិតលេខ ១១៩៦/០៩/របវត/អគជ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការលើកពេលប្រជុំក្រុមប្រឹក្សាភិបាលលើទី១១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

## ខ.ការងារកំណែទម្រង់

- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ ជួបជាមួយអនុប្រធានរដ្ឋបាលតុលាការខ្មែរក្រហម ដើម្បីពិភាក្សាស្វែងយល់អំពីការរៀបចំរដ្ឋបាលតុលាការ កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩

- បានរៀបចំកិច្ចប្រជុំកុមប្រត្តិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធមិនៅកម្ពុជា នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ដើម្បី ពិភាក្សាទៅលើយុទ្ធសាស្ត្រដកថយរបស់គម្រោងនៅសណ្ឋាគារ អ៊ីមភើរាល (Imperial Hotel)

- បានរៀបចំកិច្ចប្រជុំជាមួយមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងវិស័យកងកជន ដើម្បីពិភាក្សាទៅលើគម្រោងរៀបចំការ ស្ទង់មតិអំពីការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាដែលផ្តួចផ្តើម ឡើងក្រសួងវប្បធមិ និងវិចិត្រសិល្បៈ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា កំណែទម្រង់ច្បាប់ និងក្រសួងពាណិជ្ជកម្ម ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០០៩

- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិបានរៀបចំកិច្ចប្រជុំមួយក្រោមអធិបតីភាព ឯកឧត្តម ស៊ុយម៉ុងលាង អគ្គលេខាធិការ ជាមួយក្រសួង-ស្ថាប័ន ពាក់ព័ន្ធ មានថៅក្រមព្រះរាជអាជ្ញា ដើម្បីពិភាក្សាផ្តល់យោបល់ទៅលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីរដ្ឋបាលសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៩ វេលា ម៉ោង ១៥ៈ០០ នាទីរសៀល នៅទីស្តីការគណៈរដ្ឋមន្ត្រី

- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិបានរៀបចំកិច្ចប្រជុំ ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ មានថៅក្រម ព្រះរាជអាជ្ញា ដើម្បីរៀបចំ “កម្រងសេវាយុត្តិធមិ” ក្រោមអធិបតីភាពរបស់ ឯកឧត្តម សួង លាងហៃ អគ្គលេខាធិការង ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩

-បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០០៩ នៅសណ្ឋាគារសាន់វ៉េ Sunway Hotel

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិបានរៀបចំពិនិត្យនិងចំបោះពុម្ពផ្សាយ នូវព្រឹត្តប័ត្រលេខ៣ ឆ្នាំទី២

- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ ជួបជាមួយអ្នកជំនាញការអទឈ ពិនិត្យ ពិភាក្សាលើរបាយការណ៍ស្តីពីអំប៊ូស្មាន់ (Ombudsman )កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩

- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ បានជួបជាមួយជំនាញការ DIHR ពិភាក្សា បន្តកិច្ចសហប្រត្តិបត្តិការ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩

- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជួបជាមួយជំនាញការ JICA ពិភាក្សាលើ ដំណើរការអនុវត្តគម្រោងសូចនាការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ IMS កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩

**គ. ផ្សេងៗ**

- ចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួងផ្សេងៗ

-បានចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម:១-សេចក្តីព្រាងច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ និង ២-បញ្ហាផ្សេងៗ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០ នាទីព្រឹក

- បានចូលរួមជាកិត្តិយសក្នុងពិធីបិទសិក្ខាសាលា ស្តីពី“ការប្រយុទ្ធទប់ស្កាត់អំពើចារកម្ម ការចរាចរ និងជួញដូរវត្ថុបូរាណខុសច្បាប់ ”រៀបចំឡើងដោយអង្គការយូណេស្កូកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិ យូណេស្កូកម្ពុជា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ១៥ៈ៤៥នាទី“ពិធីបិទចាប់ផ្តើម”

- បានចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធជានិមិត្តរូប របស់វិទ្យាស្ថាន Khong ZI ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួល បន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ០៨ៈ៣០ នាទី “ ចាប់ផ្តើមពិធី”

- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីប្រកាសនិងផ្សព្វផ្សាយអំពី “ការប្រព្រឹត្តទៅរបស់គណៈវិស្វករកម្ពុជា” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង៣ៈ៣០នាទី នៅសណ្ឋាគារ ណាហ្គាវើល

- ទទួលជួបសម្ភាសន៍ជាមួយ “វិទ្យុមាតុភូមិយើង ” ស្តីពីអង្គភាពនីតិកម្មកាលពីថ្ងៃ២៣ ខែធ្នូ ឆ្នាំ២០០៩

**២-សន្និដ្ឋាន**

ក្នុងខែធ្នូ ឆ្នាំ២០០៩ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអគ្គលេខា-ធិការដ្ឋាន ជាសេនាធិការបានសម្រេចនូវសមិទ្ធផលជាអាទិ៍មានៈ រៀបចំកិច្ចក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការប្រចាំឆ្នាំ បានបញ្ចប់ការពិភាក្សាផ្តល់យោបល់ទៅលើសេចក្តីព្រាងអនុក្រឹត្យស្តីពីរដ្ឋបាលសាលាជម្រះក្តីកម្ពុជា បានរៀបចំប្រជុំក្រុមប្រត្តិបតិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា បានប្រជុំពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំ កម្រងសេវាយុត្តិធម៌ ព្រមទាំងបានបញ្ចប់នូវរបាយការណ៍ស្តីពីការសិក្សាប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា ។

**៣-ទិសដៅអនុវត្តក្នុងខែបន្ត**

- បន្តពិភាក្សាស្តីពីសេចក្តីព្រាងអនុក្រឹត្យស្តីពីរដ្ឋបាលតុលាការ
- បន្តអនុវត្តគម្រោងតុលាការគំរូ
- បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-រៀបចំកិច្ចប្រជុំក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា ដោយសហការជាមួយ UNDP

- បញ្ចប់របាយការណ៍ស្តីពីប្រព័ន្ធអំប៊ុដ្ស្មាន់នៅកម្ពុជា

- បន្តសិក្សារៀបចំផែនការសកម្មភាពជំនួយផ្នែកច្បាប់

-បន្តអនុវត្តគម្រោងកិច្ចសហប្រត្តិបត្តិការជាមួយ GTZ ជាពិសេសក្នុងការរៀបចំមូលដ្ឋានទិន្នន័យស្តីពីមុខងារស្ថាប័នរដ្ឋ

- បន្តគម្រោង UNDP ស្តីពីទិន្នន័យដៃគូអភិវឌ្ឍន៍ទាក់ទងនិងការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-បន្តពិភាក្សាជាមួយវិទ្យាស្ថានដាណឺម៉ាកសម្រាប់សិទ្ធិមនុស្ស “DIHR” លើការងារកិច្ច សហប្រត្តិ-បត្តិការ ឆ្នាំ២០១០

រាជធានី ភ្នំពេញ ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១០

**អ្នកធ្វើរបាយការណ៍**

**ស៊ុន សិរីវុធ**

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

**ស៊ុយ ម៉ុងលាង**